**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ....៦២....អនក្រ.បក.

# អនុក្រឹត្យ
## ស្តីពី
ប្រាក់បំណាច់របស់សមាជិករាជរដ្ឋាភិបាល
អនុរដ្ឋលេខាធិការ ទីប្រឹក្សា ព្រមទាំង មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ
ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងទៅ
*****

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៅតាមក្រសួង ស្ថាប័ន និង រដ្ឋលេខាធិការដ្ឋាន
-យោងសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

អនុវត្តការផ្តល់ប្រាក់បំណាច់បន្ថែមលើប្រាក់បៀវត្សប្រចាំខែតាមស្មារតីអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៥ ចាប់ពី ខែ មករា ឆ្នាំ ២០០៥ តទៅ ចំពោះសមាជិក សមាជិកា រាជរដ្ឋាភិបាល អនុរដ្ឋលេខាធិការ ទីប្រឹក្សា រាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី-ឧបនាយករដ្ឋមន្ត្រី ព្រមទាំងមន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការឡើងទៅ ។

**មាត្រា ២.-**

ប្រាក់បំណាច់បន្ថែមលើប្រាក់បៀវត្សប្រចាំខែនេះ ត្រូវបានកំណត់ក្នុងតារាងជូនខាងក្រោមៈ

| ប្រភេទប្រាក់បំណាច់⟶<br>មុខតំណែង↓ | ប្រាក់បំណាច់<br>តំណាង | ប្រាក់បំណាច់<br>បដិសណ្ឋារកិច្ច | ប្រាក់បំណាច់<br>បេសកកម្ម | ប្រាក់ឈ្នួល<br>ផ្ទះ ទឹក ភ្លើង | សរុប |
|---|---|---|---|---|---|
| នាយករដ្ឋមន្ត្រី | ១.១៣៧.៥០០៛ | ៩៦២.៥០០៛ | ៦១២.៥០០៛ | ៩៦២.៥០០៛ | ៣.៦៧៥.០០០៛ |
| ឧបនាយករដ្ឋមន្ត្រី | ៩១៨.៧៥០៛ | ៧៤៣.៧៥០៛ | ៤៨១.២៥០៛ | ៦៥៦.២៥០៛ | ២.៨០០.០០០៛ |
| ទេសរដ្ឋមន្ត្រី | ៨៣១.២៥០៛ | ៦៥៦.២៥០៛ | ៣៩៣.៧៥០៛ | ៥៦៨.៧៥០៛ | ២.៤៥០.០០០៛ |
| រដ្ឋមន្ត្រី | ៧៤៣.៧៥០៛ | ៥៦៨.៧៥០៛ | ៣០៦.២៥០៛ | ៤៨១.២៥០៛ | ២.១០០.០០០៛ |
| រដ្ឋលេខាធិការ | ៧០០.០០០៛ | ៤៨១.២៥០៛ | ២៦២.៥០០៛ | ៣០៦.២៥០៛ | ១.៧៥០.០០០៛ |
| អនុរដ្ឋលេខាធិការ | ៥២៥.០០០៛ | ៣៥០.០០០៛ | ២៦២.៥០០៛ | ២៦២.៥០០៛ | ១.៤០០.០០០៛ |

**មាត្រា ៣.-**

មន្ត្រីជាន់ខ្ពស់ដូចកំណត់ក្នុងមាត្រា ១ ដែលមានមុខតំណែងពីរ ឬ បី មានសិទ្ធិទទួលប្រាក់បំណាច់ខាងលើ បានតែមួយមុខតំណែង ក្នុងតំណែងណាមួយក៏បាន ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៩ ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ